**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## ផ្ញើជូន

## លោកជំទាវ កែវ ចន្ថា ព្រមទាំងក្រុមគ្រួសារ

*លោកជំទាវជាទីរាប់អាន,*

ភរិយាខ្ញុំ និងរូបខ្ញុំបានទទួលដំណឹងដ៏ក្រៀមក្រំ ក្តុកក្តួល និងសោកស្តាយរកអ្វីមកប្រៀបផ្ទឹមពុំបានពេលទទួលដំណឹងថា ឯកឧត្តមនាយឧត្តមសេនីយ៍ **ខូវ ឈាវ** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ទទួលមរណភាពក្នុងជន្មាយុ ៧០ ឆ្នាំ ដោយរោគាពាធ ។

មរណភាពរបស់ឯកឧត្តម **ខូវ ឈាវ** គឺជាការបាត់បង់ស្វាមី បិតា ជីតាប្រកបដោយព្រហ្មវិហារធម៌ និងក៏ដូចជាការបាត់បង់នូវនាយទាហានជាន់ខ្ពស់មួយរូប ដែលមួយជីវិតរបស់លោក បានលះបង់កម្លាំងកាយ ចិត្ត បម្រើប្រទេសជាតិ និងប្រជាជន ដើម្បីរួមចំណែកស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធឯកឧត្តម **ខូវ ឈាវ** បានចាប់កំណើតក្នុងសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកជំទាវទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*ថ្ងៃ អាទិត្យ ២កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២០*

**ហ៊ុន សែន**